## (2) លិខិតបញ្ជាក់ការចុះបញ្ជីត្រា




- ជាឯកសារបញ្ជាក់ថាជាត្រា (ត្រាហាងកុ) ដែលបានចុះបញ្ជី
  → សូមធ្វើការស្នើសុំទៅភូមិឃុំស្រុកដែលអ្នករស់នៅ ដោយបង្ហាញប័ណ្ណចុះបញ្ជីត្រាជាដើម។
- មានភូមិឃុំស្រុកខ្លះ អាចទទួលបាននៅផ្សារម៉ាត ដោយប្រើកាតលេខសំគាល់បុគ្គល។

# 2 ប្រព័ន្ធលេខសំគាល់បុគ្គល

## 2-1 តើអ្វីជាប្រព័ន្ធលេខសំគាល់បុគ្គល



- គេត្រូវការលេខសំគាល់បុគ្គលសម្រាប់ករណីដូចតទៅ៖

① នៅពេលទទួលប្រាក់សោធន ឬប្រាក់ឧបត្ថម្ភសម្រាប់ចិញ្ចឹមកូន ឬទទួលសេវាព្យាបាល
② នៅពេលផ្ញើប្រាក់ទៅបរទេស ឬនៅពេលទទួលប្រាក់ដែលផ្ញើមកពីបរទេស
③ នៅពេលបង្កើតគណនីនៅធនាគារ

- នៅពេលប្រើលេខសំគាល់បុគ្គល

① តើលេខនោះពិតជាលេខសំគាល់បុគ្គលរបស់អ្នកពិតប្រាកដមែនដែរឬទេ
② គេធ្វើការពិនិត្យបញ្ជាក់ថា តើអ្នកនិងមនុស្សដែលនៅក្នុងលិខិតបញ្ជាក់មានរូបថតដូចជាលិខិតឆ្លងដែនជាដើម ពិតជាមនុស្សតែម្នាក់ដែរឬទេ។ ហេតុដូច្នេះហើយ គ្មាននរណាម្នាក់អាចបន្លំប្រើលេខសំគាល់បុគ្គលរបស់អ្នកបានឡើយ។

## 2-2 កាតលេខផ្ទាល់ខ្លួន (កាតលេខរបស់ខ្ញុំ)

កាតលេខសំគាល់បុគ្គលជាកាតដែលមានបង្កប់ ឈីបដែលគេត្រូវការដើម្បីអោយការរស់នៅប្រទេសជប៉ុនមានភាពងាយស្រួល។

### (1) កំណត់ត្រា

ផ្ទៃខាងមុខ៖ ឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ភេទ រូបថត សុពលភាព
ផ្ទៃខាងក្រោយ៖ លេខសំគាល់បុគ្គល




ផ្ទៃខាងមុខ៖




ផ្ទៃខាងក្រោយ៖

### (2) តើគេប្រើលេខសំគាល់បុគ្គលនៅពេលណា

- ប្រើប្រាស់ជាលិខិតបញ្ជាក់អត្តសញ្ញាណសាមីខ្លួនជាផ្លូវការ
- ធ្វើការប្រកាសពន្ធលើប្រាក់ចំណូលតាមអនឡាញ
- ធ្វើការស្នើសុំតាមអនឡាញនូវប្រាក់ឧបត្ថម្ភពាក់ព័ន្ធនឹងកូន ឬស្នើសុំចូលទារកដ្ឋាន
- ទទួលយកសេចក្ដីចម្លងលិខិតបញ្ជាក់ការស្នាក់នៅវិញ្ញាបនបត្រផ្សេងៗនៅផ្សារម៉ាត(ថ្ងៃសម្រាកក៏បាន។ មានស្រុកឃុំភូមិខ្លះដែលមិនអាចយកសេចក្ដីចម្លងលិខិតបញ្ជាក់ការស្នាក់នៅតាមផ្សារម៉ាតក៏មានដែរ)
- ប្រើប្រាស់ធ្វើជាប័ណ្ណសមាជិករបបថែទាំសុខភាព (ការប្រើកាតលេខបុគ្គលរបស់អ្នកនៅតាមគ្រឹះស្ថានវេជ្ជសាស្ត្រ និងឱសថស្ថាននឹងអនុញ្ញាតឱ្យអ្នកចែករំលែកព័ត៌មានសុខភាព និងព័ត៌មានវេជ្ជសាស្ត្ររបស់អ្នកជាមួយអ្នកផ្ដល់សេវាថែទាំសុខភាពសម្រាប់ការថែទាំសុខភាពកាន់តែប្រសើរឡើង។)

ស្ថាប័នពេទ្យ និងឱសថស្ថានដែលអាចប្រើបាន មាននៅក្នុងគេហទំព័រខាងក្រោមនេះ។
https://www.mhlw.go.jp/stf/index_16743.html

### (3) វិធីស្នើសុំ

នៅពេលដែលមានអាសយដ្ឋានរស់នៅប្រទេសជប៉ុនជាក់លាក់រួច ហើយទៅជូនដំណឹងដល់ភូមិឃុំស្រុកអំពីការផ្លាស់លំនៅចូល អាចដាក់ពាក្យស្នើសុំកាតលេខសំគាល់បុគ្គល (លើកលែងមួយភាគ)។

នៅពេលស្នើសុំលើកដំបូងគឺមិនមានការគិតប្រាក់ឡើយ។

ចំពោះអ្នកដែលមិនអាចស្នើសុំបាននៅពេលទៅជូនដំណឹងដល់ភូមិឃុំស្រុកអំពីការផ្លាស់លំនៅចូល និងបានទទួលពាក្យស្នើសុំកាតលេខសំគាល់បុគ្គលដែលនឹងត្រូវបានផ្ញើទៅដល់ផ្ទះ សូមប្រើប្រាស់ពាក្យស្នើសុំនោះដើម្បីធ្វើការស្នើសុំតាមវិធីខាងក្រោម៖

1 ការស្នើសុំតាមទូរស័ព្ទស្មាតហ្វូន
ថតរូបមុខដោយទូរស័ព្ទស្មាតហ្វូន ហើយចូលទៅកាន់ វែបសាយសម្រាប់ស្នើសុំ តាមរយៈ QR កូដនៅក្នុងពាក្យស្នើសុំ

2 ការស្នើសុំតាមកុំព្យូទ័រ
ថតរូបមុខដោយកាមេរ៉ាឌីជីថល ហើយចូលទៅកាន់ វែបសាយសម្រាប់ស្នើសុំ

3 ការស្នើសុំតាមប្រៃសណីយ៍
បិទរូបថតនៅលើពាក្យស្នើសុំ ហើយបំពេញព័ត៌មានចាំបាច់ ដាក់ចូលក្នុងស្រោមសំបុត្រសម្រាប់ផ្ញើ ហើយដាក់ចូលក្នុងប្រអប់ប្រៃសណីយ៍

4 ការស្នើសុំតាមម៉ាស៊ីនថតរូបសម្រាប់បញ្ជាក់ (ចំពោះតែប្រភេទម៉ាស៊ីនដែលមានមុខងារនោះប៉ុណ្ណោះ)
ចុចលើប្រដាប់បញ្ជាលើអេក្រង់ ដាក់ប្រាក់ចូល ដាក់ QR កូដនៅក្នុងពាក្យស្នើសុំអោយប្រដាប់អានបាកូដអាន។ បំពេញព័ត៌មានត្រូវការចំបាច់ ថតរូប ហើយបញ្ជូន។

5 ការស្នើសុំនៅបញ្ជរទទួលភ្ញៀវរបស់រដ្ឋបាលភូមិឃុំស្រុក (លើកលែងករណីខ្លះ)
បំពេញព័ត៌មានត្រូវការចំបាច់នៅក្នុងពាក្យស្នើសុំ ហើយដាក់ជូនទៅអោយភូមិឃុំស្រុកដែលខ្លួនរស់នៅ

* នៅពេលធ្វើការស្នើសុំនៅភូមិឃុំស្រុកបន្ទាប់ពីផ្ទៀងផ្ទាត់អត្តសញ្ញាណសាមីខ្លួន គេអាចទទួលយកកាតលេខសំគាល់បុគ្គលតាមប្រៃសណីយ៍បាន។

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖
https://www.kojinbango-card.go.jp/en-kofushinse/

## (4) វិធីទទួលយក

1ខែក្រោយពីការស្នើសុំ គេនឹងទទួលបានកាតប៉ុស្តាល់ពីភូមិឃុំស្រុក។
សូមយកមកជាមួយនូវកាតប៉ុស្តាល់នោះនិងឯកសារត្រូវកាចាំបាច់ដើម្បីទៅទទួលយកកាតលេខសំគាល់បុគ្គលរបស់អ្នក។

ចំពោះខ្លឹមសារលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖
https://www.kojinbango-card.go.jp/en-uketori/

# 2-3 ប្រការប្រុងប្រយ័ត្នក្នុងការប្រើកាតលេខសំគាល់បុគ្គល

- ក្នុងករណីដែលមានការផ្លាស់ប្តូរនូវឈ្មោះ អាសយដ្ឋាន ជាដើម សូមធ្វើការជូនដំណឹងទៅភូមិឃុំស្រុកដែលអ្នករស់នៅ។
- កាលកំណត់សុពលភាពនៃកាតលេខសំគាល់បុគ្គល គឺដូចគ្នានឹងថ្ងៃបញ្ចប់នៃកម្លងពេលនៃការស្នាក់នៅដែរ។
- បន្ទាប់ពីបន្តរយៈពេលនៃការស្នាក់នៅរបស់អ្នក សូមបន្តសុពលភាពនៃប័ណ្ណលេខបុគ្គលរបស់អ្នកនៅការិយាល័យក្រុងដែលអ្នករស់នៅ មុនពេលវាផុតកំណត់។

* ទោះជាសុពលភាពនៃរយៈពេលស្នាក់នៅត្រូវបានបន្តក៏ដោយ ក៏សុពលភាពនៃកាតលេខសំគាល់បុគ្គលមិនត្រូវបានបន្តដោយស្វ័យប្រវត្តិឡើយ។ ប្រសិនបើកាតលេខបុគ្គលរបស់អ្នកផុតកំណត់ កាតនេះនឹងត្រូវគិតថ្លៃ ដើម្បីចេញកាតឡើងវិញ។

* ត្រូវប្រយ័ត្នអំពីកម្លងពេលពិសេស ដែលកើតមានឡើងនៅពេលសុំការស្នាក់នៅ។
ក្នុងករណីដែលមិនអាចទទួលការអនុញ្ញាតការពន្យារការស្នាក់នៅ ឱ្យបានមុនពេលផុតសុពលភាពកាតលេខសម្គាល់បុគ្គល ចាំបាច់ត្រូវទៅសុំពន្យារសុពលភាពកាតលេខសម្គាល់បុគ្គល 2ខែ (កម្លងពេលពិសេស)។
នៅពេលដែលបានទទួលប័ណ្ណស្នាក់នៅថ្មី ចាំបាច់ទៅពន្យារសុពលភាពនៃកាតលេខសម្គាល់បុគ្គលឱ្យបានស្មើនឹងថ្ងៃបញ្ចប់នៃកម្លងពេលនៃការស្នាក់នៅថ្មី ម្តងទៀត។

ចំពោះសេចក្តីលំអិត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម។
https://www.soumu.go.jp/main_sosiki/jichi_gyousei/c-gyousei/zairyu/english/basic_resident_registration_card.html

## 2-4 ផ្សេងៗ

ចំពោះខ្លឹមសារផ្សេងទៀត សូមពិនិត្យមើលនៅគេហទំព័រខាងក្រោម៖

ប្រព័ន្ធលេខសំគាល់បុគ្គល
https://www.digital.go.jp/policies/mynumber/

កាតលេខសំគាល់បុគ្គល
https://www.kojinbango-card.go.jp/en/

យើងទទួលការសាកសួរតាមទូរស័ព្ទផងដែរ។

សេវាព័ត៌មានតាមទូរស័ព្ទ
(ច័ន្ទ ~ សុក្រ 9:30 - 20:00 ថ្ងៃសៅរ៍ ថ្ងៃអាទិត្យនិងថ្ងៃបុណ្យ 9:30 - 17:30)

◎ ភាសាជប៉ុន
TEL 0120-95-0178

◎ English, Chinese, Korean, Spanish, Portuguese
TEL 0120-0178-27